<u>វេទិកា</u>

<u>ស្ដីពីភាពជាដៃគូរវាង</u>

<u>រដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល</u>

<u>ថ្ងៃ២ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២</u>
<u>ត្រូវនឹងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨</u>

សុន្ទរកថារបស់លោក **សឿង សារឿន** ប្រធានអង្គការ

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) និងជាតំណាងអង្គការសង្គមស៊ីវិល

---

**សូមគោរព! សម្ដេច ទ្រង់ ឯកឧត្ដម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា បង ប្អូន ជាភ្ញៀវជាតិ និងអន្តរជាតិ និង អង្គវេទិកាទាំងមូល!**

ក្នុងនាមគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដែលជាអង្គការសមាជិកភាពធំជាងគេនៅក្នុងប្រទេសកម្ពុជា ហើយដែលមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ជាង១៧០ ជាសមាជិក ធ្វើការងារជាដៃគូដើម្បីការលើកកំពស់អភិបាលកិច្ចល្អ បរិយាកាសអំណោយផល និងនិរន្តរភាពរបស់អង្គការស៊ីវិលនៅកម្ពុជា ខ្ញុំសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងមហាផ្ទៃ ដែលបានរៀបចំ និងអនុញ្ញាតឲ្យខ្ញុំបាទ និងសហសេវិកពីសង្គមស៊ីវិលបានចូលរួមក្នុង<u>**វេទិកា**</u> <u>**ស្ដីពីភាពជាដៃគូរវាង រដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល**</u> នាថ្ងៃនេះ។

យោងតាមការអនុញ្ញាតពី**សម្តេច ក្រឡាហោម ស ខេង** ប្រធានរៀបចំវេទិកាទាំងមូល និងរបៀបវារៈ ខ្ញុំបាទសូមផ្តោតការចូលរួមជាពិសេសទៅលើ **របាយការណ៍អំពីស្ថានភាពទូទៅ នៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល** ក្រោយច្បាប់សមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន ខ្ញុំបាទសូមចូលរួមធ្វើការកត់សម្គាល់ ទៅលើចំនុចមួយចំនួនដូចតទៅនេះ ៖

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយមានកិច្ចសហប្រតិបត្តិការល្អរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ទើបជំរុញឲ្យសង្គមស៊ីវិលបានដើរតួនាទីយ៉ាងសំខាន់របស់ខ្លួនក្នុងការចូលរួមចំណែកការអភិវឌ្ឍប្រទេសកម្ពុជា។ តួយ៉ាងការសិក្សារួមមួយក្នុងចំណោមសង្គមស៊ីវិលជិត ២០០០(ពីរពាន់)អង្គការ កាលពីឆ្នាំ២០១២ បង្ហាញថាសង្គមស៊ីវិល ចំណាយទឹកប្រាក់សរុបប្រមាណជាង ៦០០ ទៅ ៧០០ លានដុល្លាក្នុងមួយឆ្នាំៗ

សម្រាប់ចូលរួមក្នុងការអភិវឌ្ឍប្រទេសកម្ពុជា និងអ្នកទទួលផលដោយផ្ទាល់និងដោយប្រយោលជិត១២លាននាក់[1]។

**សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីគោរព!**

សមិទ្ធិផលសំខាន់ៗ និងវឌ្ឍនភាពជាច្រើន ដែលកើតឡើងតាមរយៈភាពជាដៃគូរវាងសង្គមស៊ីវិលជាមួយរាជរដ្ឋាភិបាលដោយផ្ទាល់ក្តី និងប្រយោលក្តី មានដូចជា៖ ១) ការឆ្លើយតបនឹងគ្រោះមហន្តរាយធម្មជាតិ និងជំងឺរាតត្បាតនានា ពិសេសការកាត់បន្ថយការរីករាលដាលមេរោគអេដស៍ ២) ការចូលរួមពង្រឹងគុណភាពសេវានានាជាពិសេសសេវាអប់រំ សុខាភិបាល និងអភិវឌ្ឍជនបទរួមទាំងអនាម័យទូទៅ និងគមនាគមន៍ជនបទ, ៣) ការលើកកំពស់ការយល់ដឹងអំពីប្រជាធិបតេយ្យ សិទ្ធិមនុស្ស សមភាពយេនឌ័រ តាមរយៈការអប់រំផ្សព្វផ្សាយសិទ្ធិជាមូលដ្ឋាន និងការជំរុញការចូលរួមរបស់ប្រជាពលរដ្ឋយ៉ាងសកម្មក្នុងដំណើរការអភិវឌ្ឍន៍ ៤) ការអភិវឌ្ឍធនធានមនុស្សដល់ប្រជាពលរដ្ឋជាក្រុមគោលដៅផង អាជ្ញាធរ និងមន្ត្រីរដ្ឋាភិបាល ៥) ការលើកកម្ពស់ជីវភាពរស់នៅ និងមុខរបរ និង ៦) ការលើកកំពស់ការអភិរក្សធនធានធម្មជាតិ និងការប្រយុទ្ធប្រឆាំងនឹងបំរែបំរួលអាកាសធាតុ និង វិស័យជាអាទិភាពជាច្រើនទៀត ស្របតាមគោលនយោបាយអភិវឌ្ឍន៍ជាតិ និង ថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាបាល។

**សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីគោរព!**

អង្គការសង្គមស៊ីវិលសូមស្វាគមន៍នូវការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងភាពជាដៃគូជាច្រើននាពេលកន្លងមក ក៏ដូចជាទទួលស្គាល់សមិទ្ធិផលជាច្រើនដែលកើតចេញពីការអភិវឌ្ឍស្ទើរគ្រប់វិស័យ ពិសេសការខិតខំឆ្លើយតបប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងនិរន្តរភាពទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី កុមារ និងជនងាយរងគ្រោះ។ បើទោះបីជា**ស្ថានភាពទូទៅ នៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល** មានភាពល្អប្រសើរគួរអោយកត់សម្គាល់ជិតបីទសវត្សន៍កន្លងមក ប៉ុន្តែនាពេលជាងមួយឆ្នាំចុងក្រោយនេះ សង្គមស៊ីវិលបានមានរងនូវក្តីព្រួយបារម្ភមួយចំនួនរួមមាន៖ ១) **ការថយចុះកិច្ចសហការណ៍ពីសំណាក់អាជ្ញាធរមូលដ្ឋាន** ក្នុងការសម្របសម្រួលការអនុវត្តគម្រោងរបស់អង្គការសង្គមស៊ីវិលដោយហេតុផលនិតិ រដ្ឋបាលនានា ដូចជាការតម្រូវឲ្យមានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាននូវរាល់ពេលអង្គការអង្គការសង្គមស៊ីវិលធ្វើសកម្មភាពរបស់ខ្លួន បើទោះបីជាសកម្មភាពទាំងនោះសុទ្ធតែធ្លាប់បានអនុវត្តនៅក្នុងមូលដ្ឋានរួចមកហើយក្តី ក៏ប៉ុន្តែមានការតម្រូវពីអាជ្ញាធរមូលដ្ឋាន ក្នុងការចុះបញ្ជីសកម្មភាព ដែលទាំងនេះមិនមានចែងក្នុងច្បាប់ស្តីពីសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ២) **ការភ្ជាប់អង្គការសង្គមស៊ីវិលទៅនឹងបរិបទនយោបាយ និងចលនាប្រឆាំងនានា** ដូចជាការអង្គការសង្គមស៊ីវិលចូលរួមក្នុងបដិវត្តន៍ពណ៌ជាដើម។ ៣) ការ

[1] CSO Contribution to the Development of Cambodia (2012)

អនុវត្តក្របខណ្ឌគតិយុទ្ធដែលពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិលយ៉ាងគំហុក មិនមានស្តង់ដារួម និងខ្វះយន្តការគាំទ្រគ្រប់កំរិត ព្រមទាំងការឆ្លើយតបមិនទាន់ពេលវេលា ដែលធ្វើឲ្យពួកគេមិនអាចឆ្លើយតប និងបំពេញកតាព្វកិច្ចបានសមស្របទាន់ពេលវេលាបាន។

ថ្ងៃនេះខ្ញុំបាទក៏សូមធ្វើការកត់សម្គាល់នូវសំណើមួយចំនួន ដែលបានទទួលពីការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលមួយចំនួនធំនៅកំរិតថ្នាក់ជាតិ និងក្រោមជាតិ ដូចខាងក្រោម៖

<u>សំណើសុំសំខាន់ៗ</u>៖

- គួរមានក្រុមការងារបច្ចេកទេសចម្រុះដែលមានតំណាងពីក្រសួងពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល ដើម្បីពិភាក្សា និងរកដំណោះស្រាយ ល្អបំផុតចំពោះបញ្ហាពាក់ព័ន្ធនឹងច្បាប់ស្តីពីសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់នានាដែលពាក់ព័ន្ធអង្គការសង្គមស៊ីវិល។
- បង្កើតយន្តការភាពជាដៃគូពហុភាគី (រដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍ) ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) និង ភាពជាដៃគូជាមួយរដ្ឋាភិបាលបើកទូលាយ (OGP) ដែលនឹងជំរុញឲ្យមានជំនឿទុកចិត្តចំពោះគ្នា មានសេចក្តីសង្ឃឹម សេចក្តីស្រឡាញ់ និងសាមគ្គីភាពយ៉ាងស្អិតរមួតដើម្បីសម្រេចនូវបំណងប្រាថ្នារួមនេះ និងជាពិសេសគឺដើម្បីជម្រុញឲ្យ**ព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍប្រកបដោយប្រជាធិបតេយ្យ និងចីរភាពជានិរន្ត** សម្រាប់ជា**មរតកដ៏ថ្លៃថ្លា**ដល់**អ្នកជំនាន់ក្រោយៗ**របស់ពួកយើង។
- រាជរដ្ឋាភិបាលគួរនិរាករណ៍នូវប្រកាសអន្តរក្រសួងលេខ ១៧០ ប្រក.អន្តរក្រ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០១៨ ព្រោះខ្លឹមសារមានលក្ខណៈទូលាយ និងអាចមានផលវិបាកជាអវិជ្ជមានក្នុងការអនុវត្ត។ រាជរដ្ឋាភិបាលគួរផ្តោតសំខាន់អោយមានសេចក្តីពន្យល់អត្ថន័យ និងនិយមន័យមាត្រាមួយចំនួន "ច្បាប់ស្តីពីសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល" ឱ្យកាន់តែច្បាស់ដើម្បីជៀសវាងការយល់ផ្សេងគ្នា និងបកស្រាយខុសៗគ្នា។ ជាមួយគ្នានេះគួរពន្លឿនការអនុមតិច្បាប់ស្តីអំពីសិទ្ធទទួលបានព័ត៌មាន និងធានានូវសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលដ្ឋក្នុងការសម្រេចចិត្តលើវិស័យនយោបាយ សេដ្ឋកិច្ចសង្គមជាដើម។
- ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធនានាគួររៀបចំឲ្យមានការផ្សព្វផ្សាយ លើកកម្ពស់ការយល់ ដឹងច្បាប់ក៏ដូចជានីតិវិធីអនុវត្តន៍ ព្រមទាំងមានជនបង្គោល ឬមន្រ្តីទំនាក់ទំនងច្បាស់លាស់ សម្រាប់ពេលមានបញ្ហាពាក់ព័ន្ធនឹងការអនុវត្តន៏ច្បាប់ដែលពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល។ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្មគួរត្រូវបានពន្យាពេលអនុវត្តចំពោះអង្គការសង្គមស៊ីវិល ដោយសង្គមស៊ីវិលពុំទាន់យល់ និងត្រៀមខ្លួនរួចរាល់ ក្នុងការរៀបចំ និងអនុវត្តប្រព័ន្ធគណនេយ្យហិរញ្ញវត្ថុទៅតាមតម្រូវការរបស់រាជរដ្ឋាភិបាល។ ប្រព័ន្ធ

គណនេយ្យហិរញ្ញវត្ថុរបស់អង្គការសង្គមស៊ីវិលមានការត្រួតពិនិត្យ និងសវនកម្មសំណាក់ម្ចាស់ជំនួយ ។ អង្គការសហគមន៍មូលដ្ឋានភាគច្រើនបំផុត ត្រូវការឱ្យមាន ការគាំទ្រនិងពង្រឹងសមត្ថភាព និងធនធានសមស្របសម្រាប់បន្ថែមទៀត មុនពេលដែលពួកគាត់អាចរៀបចំប្រព័ន្ធគណនេយ្យហិរញ្ញវត្ថុផ្ទៃក្នុងស្របទៅតាមការតម្រូវរបស់រដ្ឋាភិបាល។

- រាជរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារគួរផ្តល់ការលើកទឹកចិត្តដល់អង្គការ សមាគមន៍ទាំងឡាយណាដែលបានចុះបញ្ជីជាមួយក្រសួងមានសមត្ថកិច្ច ហើយមិនទាន់បានចុះបញ្ជីពន្ធដារ ព្រមទាំងមិនទាន់បានបង់ពន្ធត្រឹមត្រូវ ឲ្យពួកគេមានឱកាសបានបំពេញកាតព្វកិច្ចត្រឹមត្រូវស្របតាមច្បាប់សារពើពន្ធ ដោយមិនមានការផាកពិន័យ និងទោសទាន់ឡើយ។ ម្យ៉ាងវិញទៀត បុគ្គលិក អង្គការសង្គមស៊ីវិលគួរត្រូវបានគិតគូរយ៉ាយយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលនូវអត្ថប្រយោជន៍នានា ដូចជាប្រាក់សោធននិវត្សន៍ ជាដើម។ល។
- ក្រសួងពាក់ព័ន្ធគួរមានការសម្របសម្រួល និងការឆ្លើយតបជាលក្ខណៈប្រព័ន្ធ និងដោយប្រើប្រាស់ប្រព័ន្ធបច្ចេកទេសស្វ័យប្រវត្តិ (online) ដើម្បីកាត់បន្ថយភាពស្មុគស្មាញនៃកិច្ចការរដ្ឋបាលដូចជាការចុះឈ្មោះការដាក់ជូនរបាយការណ៍ ការជូនដំណឹង ការទទួលស្គាល់ថ្នាក់ដឹកនាំ និងការចុះអនុស្សរណៈឡើងវិញសម្រាប់អង្គការបរទេស ការផ្ញើរបាយការណ៍ និងការជូនដំណឹងមុននឹងអនុវត្តសម្មភាពជាដើម។
- អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាលយ៉ាងហោចណាស់គួរជួបប្រជុំប្រចាំឆ្នាំ ដើម្បីឆ្លុះបញ្ចាំងពីសមិទ្ធិផល លើកកំពស់ភាពជាដៃគូ និងឆ្លុះបញ្ចាំងពីការអនុវត្តគោលនយោបាយនានា និងច្បាប់ស្តីពីសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត។

**សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីស្នេហា!**

ខ្ញុំបាទសង្ឃឹមមថា សំណើខាងលើនេះនឹងត្រូវបានឆ្លើយតបពីសំណាក់រាជរដ្ឋាភិបាលជាវិជ្ជមាននៅក្នុងវេទិកានេះ និងឱកាសបន្តបន្ទាប់ជាច្រើនទៀត។

ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថា សង្គមស៊ីវិលប្តេជ្ញាចិត្តនឹងដើរតួនាទីយ៉ាងសំខាន់ក្នុង**ការពិភាក្សាអំពីគោលនយោបាយនានា** ជាមួយរដ្ឋាភិបាល ចូលរួម**ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស** ក៏ដូចជាចូលរួមក្នុងការ**ពង្រឹងភាពជាដៃគូពហុភាគី** និង**ការបំពេញតួនាទីផ្សេងៗ**ជាច្រើនទៀតសម្រាប់គាំទ្រដល់ការ**អភិវឌ្ឍប្រកបដោយប្រជាធិបតេយ្យ និងចីរភាពសម្រាប់ ប្រទេសកម្ពុជា**។ ដើម្បីធានាការចូលរួមរបស់អង្គការសង្គមស៊ីវិលឲ្យមានភាពពេញលេញ និងប្រកបទៅដោយគុណភាព យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សង្គមស៊ីវិលនឹងទទួលបាននូវ**បរិយាកាសអំណោយផល លំហប្រជាធិបតេយ្យ កិច្ចសហប្រតិបត្តិការ** និងមានការអនុវត្តក្របខណ្ឌច្បាប់ប្រកបដោយគតិយុទ្ធ សុចរិត យុត្តិធម៌ និងមិនលំអៀង។

មុននឹងបញ្ចប់ ខ្ញុំសូមសម្តែងការកោតសរសើរ និងថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំនិងសហការីទាំងអស់របស់ **ក្រសួងមហាផ្ទៃ** ជាពិសេស**សម្តេច ក្រឡាហោម ស ខេង** ដែលជានិច្ចកាល តែងតែជួយគាំទ្រដល់ អង្គការសង្គមស៊ីវិល ឲ្យបន្តនូវបេសកម្មរបស់ខ្លួន ក្នុងភាពជាដៃគូប្រកបដោយបរិយាបន្នក្នុងការអភិវឌ្ឍ។

ខ្ញុំសូមជូនពរ **សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី** ឲ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមឲ្យវេទិកាថ្ងៃនេះសម្រេចបានជោគជ័យ។

សូមអរគុណ!